DECENT WORK
A better world starts here.

International Labour Organization

Press Release សេចក្តីប្រកាសព័ត៌មាន

# អង្គការពលកម្មអន្តរជាតិ (ILO) ស្វាគមន៍ចំពោះកិច្ចព្រមព្រៀងរួមគ្នា នៅក្នុងឧស្សាហកម្មកាត់ដេរប្រទេសកម្ពុជា

សម្រាប់ការផ្សាយជាបន្ទាន់៖ ថ្ងៃ ព្រហស្បតិ៍ ទី ៣០ ខែ កញ្ញា ឆ្នាំ ២០១០

ព័ត៌មានរបស់ ILO (ទីក្រុងបាងកក)៖ អង្គការពលកម្មអន្តរជាតិ (ILO) បានស្វាគមន៍ដល់កិច្ចព្រមព្រៀងដ៏មានសារៈសំខាន់ដែលបានសម្រេចដោយសហជីព និង និយោជកក្នុងវិស័យកាត់ដេរប្រទេសកម្ពុជា ដើម្បីធ្វើឱ្យប្រសើរឡើងនូវទំនាក់ទំនងក្នុងឧស្សាហកម្មនេះ។

អនុស្សារណៈយោគយល់គ្នា (MoU) ថ្មីត្រូវបានចុះហត្ថលេខាកាលពីថ្ងៃ អង្គារ ទី ២៨ ខែ កញ្ញា ឆ្នាំ ២០១០។ MoU នេះ គ្របដណ្តប់លើទិដ្ឋភាពសំខាន់ៗនៃអនុសញ្ញារួម ការដោះស្រាយដោយអាជ្ញាកណ្តាល និងផលិតភាព និងរួមមានវិធានការណ៍ច្បាស់លាស់ដើម្បីធ្វើការអនុវត្តន៍។ MoU នេះត្រូវបានចុះហត្ថលេខាដោយសមាគមរោងចក្រកាត់ដេរនៅកម្ពុជា (GMAC) ដែលតំណាងឱ្យរោងចក្រធំៗប្រមាណ ៣០០ រោងចក្រ ដែលផ្តល់ការងារដល់កម្មករនិយោជិតកាត់ដេរប្រហែល ៣០០.០០០ នាក់ និងត្រូវបានចុះហត្ថលេខាដោយសហភាព និងសហព័ន្ធសហជីពធំៗចំនួន ៦ ដែលតំណាងឱ្យកម្មករនិយោជិតភាគច្រើន។

យោងតាមសមាគមរោងចក្រកាត់ដេរនៅកម្ពុជា (GMAC) ក៏ដូចជា សហភាព និងសហព័ន្ធសហជីព កិច្ចព្រមព្រៀងនេះគឺជា "ដំណាក់កាលដ៏មានសារៈសំខាន់មួយ.... ដែលផ្តល់ឱ្យនូវភាពប្រសើរឡើងយ៉ាងច្រើននៅក្នុងទំនាក់ទំនងរវាងភាគីទាំងពីរ។" ក្នុងចំណោមចំនុចសំខាន់ៗនៃអនុស្សារណៈយោគយល់គ្នានេះ មានដូចជា ÷

- ការប្តេជ្ញាចិត្តដោយភាគីទាំងពីរ ដើម្បីគោរពច្បាប់
- ការប្តេជ្ញាចិត្តដោយសហជីពដែលមានសម្លេងភាគតិច ក្នុងការមិនជ្រៀតជ្រែកទៅនឹងសិទ្ធិរបស់សហជីពដែលមានសម្លេងភាគច្រើន ដើម្បីចូលរួមធ្វើអនុសញ្ញារួមជាមួយនិយោជក
- កិច្ចព្រមព្រៀង ដើម្បីប្រើប្រាស់នូវនីតិវិធីនៃសេចក្តីបង្គាប់ជាប់កាតព្វកិច្ចរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ចំពោះវិវាទលើសិទ្ធិ ការចោទប្រកាន់នូវការបំពានច្បាប់ (ឬប្រកាស) ឬក៏អនុសញ្ញារួមដែលមានស្រាប់
- កិច្ចព្រមព្រៀងដែលនឹងមិនមានឡុកអៅ កូដកម្ម ឬក៏ការស្នើសុំបន្ថែម ក្នុងអំឡុងពេលអាណត្តិនៃអនុសញ្ញារួមនាពេលបច្ចុប្បន្ន។

លើសពីនេះទៅទៀត អនុស្សារណៈយោគយល់គ្នានេះ (ដែលនឹងចូលជាធរមាននៅថ្ងៃទី ១ ខែ មករា ឆ្នាំ ២០១១) អនុញ្ញាតឱ្យភាគីទាំងពីរ ដើម្បីត្រួតពិនិត្យ និងពិនិត្យមើលឡើងវិញនូវការអនុវត្តន៍នៃកិច្ចព្រមព្រៀងនេះ។ ពួកគេព្រមព្រៀមគ្នាដើម្បីប្រព្រឹត្តទៅតាមសុចរិតភាព ដើម្បីគោរពទៅតាមអនុស្សារណៈយោគយល់គ្នានេះ ហើយប្រសិនត្រូវបានសង្ស័យថាមិនបានគោរពទៅតាមល័ក្ខខ័ណ្ឌនេះ ពួកគេព្រមព្រៀងគ្នាដើម្បីចាត់ចំណាត់ការកែលំអតាមរយៈកិច្ចសន្ទនាគ្នា។ ភាគីនីមួយៗអាចចាត់ទុកអនុស្សារណៈយោគយល់គ្នាជាមោឃៈបាន ក្នុងរយៈពេលមួយឆ្នាំបន្ទាប់ពីថ្ងៃចុះហត្ថលេខា។

ASIAN DECENT WORK DECADE 2006 2015

ILO Regional Office for Asia and the Pacific
United Nations Building, 11th Floor
Rajdamnern Nok Avenue
Bangkok 10200, Thailand

Tel. +66 2 288 1234
Fax. +66 2 288 3062
Email: bangkok@ilo.org
www.ilo.org/asia

For information only. Not an official record.

នៅក្នុងសេចក្តីប្រកាសព័ត៌មានរួម ដែលធ្វើឡើងដោយសមាគមរោងចក្រកាត់ដេរនៅកម្ពុជា (GMAC) និងសហភាព និងសហព័ន្ធសហជីពកម្ពុជា លោក វ៉ាន់ ស៊ូអៀង ប្រធានសមាគមរោងចក្រកាត់ដេរនៅកម្ពុជា បានមានប្រសាសន៍ថា "កិច្ចព្រមព្រៀងនេះ គឺជាជំហានមួយដ៏សំខាន់ដើម្បីធ្វើឱ្យប្រសើរឡើងនូវទំនាក់ទំនងរវាងសហជីព និងនិយោជក។ វាបង្ហាញអោយឃើញនូវបញ្ហាប្រឈមមួយ សម្រាប់ភាគីទាំងពីរដើម្បីអនុវត្ត ហើយសមាគមរោងចក្រកាត់ដេរនៅកម្ពុជា ប្តេជ្ញាចិត្តដើម្បីឆ្លើយតបទៅនឹងបញ្ហាប្រឈមនេះ។ ភាគីសហជីពត្រូវតែធ្វើដូចគ្នានេះផងដែរ។"

លោក អាត់ ធន់ ប្រធានសហភាពការងារកម្ពុជា បានចាត់ទុកនូវអនុស្សារណៈយោគយល់គ្នានេះជាជំហានដ៏សំខាន់ដើម្បីឆ្ពោះទៅរកការកសាងការជឿទុកចិត្តរវាងភាគីទាំងឡាយ និងប្រកាន់យកនូវនីតិរដ្ឋ។ លោកបានមានប្រសាសន៍ថា "សហជីពទាំងអស់ដែលបានចុះហត្ថលេខា នឹងធ្វើការព្យាយាមអោយបានខ្លាំងក្លាដើម្បីអនុវត្តនូវអនុស្សារណៈយោគយល់គ្នានេះ ហើយយើងរំពឹងទុក នូវការប្តេជ្ញាចិត្តដូចគ្នានេះពីខាងភាគីនិយោជកផងដែរ។ យើងត្រូវខិតខំឱ្យខ្លាំង ដើម្បីលើកកម្ពស់កិច្ចព្រមព្រៀងនេះ ទៅដល់កម្មករនិយោជិត និងនិយោជកទាំងអស់នៅក្នុងឧស្សាហកម្មកាត់ដេរ។"

លោក ហង្ស សូរិយា អនុប្រធានសម្ព័ន្ធសហជីពយុវជនខ្មែរ និងជាហត្ថលេខីមួយរូបដែរនោះ បានថ្លែងថា "អនុស្សារណៈយោគយល់គ្នានេះ ឆ្លុះបញ្ចាំងពីភាពចាស់ទុំដែលមានការរីកចម្រើនឡើង នៅក្នុងទំនាក់ទំនងរវាងភាគីទាំងពីរដើម្បីប្រើប្រាស់ការសន្ទនាគ្នា ក្នុងការសម្រេចឱ្យបាននូវកិច្ចព្រមព្រៀងលើបញ្ហាសំខាន់ៗ។"

អនុស្សារណៈយោគយល់គ្នា អនុវត្តទៅលើសមាជិកនាពេលបច្ចុប្បន្ន និងអនាគតរបស់សមាគមរោងចក្រកាត់ដេរនៅកម្ពុជា និងសមាជិកពាក់ព័ន្ធនានាក្នុងពេលបច្ចុប្បន្ន និងអនាគត (នៅថ្នាក់សហព័ន្ធ និងសហគ្រាស) នៃសហភាព និងសហព័ន្ធកម្មករនិយោជិត ដែលបានចុះហត្ថលេខាលើអនុស្សារណៈយោគយល់គ្នានេះ។ ភាគីទាំងអស់ក៏បានធ្វើការប្តេជ្ញាចិត្តដើម្បីលើកកម្ពស់នូវអនុស្សារណៈយោគយល់គ្នានេះ ទៅដល់និយោជក និងកម្មករនិយោជិត ដែលមិនមែនជាភាគីដោយផ្ទាល់នៃអនុស្សារណៈនេះ។

អនុស្សារណៈយោគយល់គ្នា ត្រូវបានភ្ជាប់ទៅជាមួយ។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង
Sophy Fisher
មន្ត្រីទំនាក់ទំនងព័ត៌មានថ្នាក់តំបន់នៃអង្គការ ILO
fisher@ilo.org
០២ ២៨៨ ២៩៨៤

លោក John Ritchotte

អ្នកឯកទេសខាងទំនាក់ទំនងការងារនៃអង្គការ ILO
ritchotte@ilo.org
០២ ២៨៨ ២២២៦

លោក Ken Loo សមាគមរោងចក្រកាត់ដេរនៅកម្ពុជាៈ +៨៥៥ ១២ ២៨២ ២៨៨

លោកស្រី ម៉ម ញឹម សម្ព័ន្ធសហព័ន្ធសហភាពការងារកម្ពុជាៈ +៨៥៥ ១២ ៨២៤ ៦៤០

លោក អាត់ ធន់ សហភាពការងារកម្ពុជាៈ +៨៥៥ ១២ ៩៩៨ ៩០៦

លោក សោម អូន សភាសម្ព័ន្ធសហជីពជាតិកម្ពុជាៈ +៨៥៥ ១២ ៨៦៦ ៦៨២

លោក រ៉ុង ឈុន  សហភាពសហជីពកម្ពុជាៈ +៨៥៥ ១២ ៩៣០ ៧០៦

លោក វង្ស សុវណ្ណ សហភាពសហព័ន្ធសហជីពជាតិកម្ពុជាៈ +៨៥៥ ១២ ៧៨៥ ៨៩០

លោក ម៉ៃ រតនា សម្ព័ន្ធសហជីពយុវជនខ្មែរៈ +៨៥៥ ១៧ ៣៧០ ៣៦៣